# ១

# មនោរា

ខ្ញុំតែងតែចំណាយពេលភាគច្រើនរបស់ខ្ញុំគិតពីនេះពីនោះ។ ខ្ញុំមិនដឹងថា ខ្ញុំគិតដើម្បីអ្វីទេ តែនេះជាទម្លាប់របស់ខ្ញុំ ហើយជាអ្វីដែលធ្វើឲ្យខ្ញុំសប្បាយចិត្តផងដែរ។ ម៉ាក់របស់ខ្ញុំតែងតែនិយាយថា គាត់ស្រលាញ់ខ្ញុំ ព្រោះខ្ញុំអាចមើលឃើញចំណុចល្អក្នុងខ្លួនមនុស្សគ្រប់គ្នា។ មិនថាអ្នកនោះ ជាមនុស្សដែលខ្ញុំស្គាល់យូរឆ្នាំ ឬទើបនឹងជួបគ្នាទេ ខ្ញុំអាចចាត់ទុកពួកគេជាមនុស្សល្អបានទាំងអស់។ ខ្ញុំជឿថា សារជាតិរបស់មនុស្ស គឺល្អ ហើយខ្ញុំជឿទៀតថា បើខ្ញុំជឿជាក់លើអ្នកណាម្នាក់ថាជាមនុស្សល្អ គេនឹងប្រឹងធ្វើខ្លួនជាមនុស្សល្អ។

រហូតដល់ថ្ងៃមួយ គ្រប់យ៉ាងដែលខ្ញុំគិត និងអ្វីដែលខ្ញុំជឿកន្លងមក ក្លាយជាកំហុសរបស់ខ្ញុំ...

### ពីរឆ្នាំកន្លងមក

ខ្ញុំឈ្មោះមនោរា។ គ្រប់គ្នាហៅខ្ញុំថា មនោរា ព្រោះខ្ញុំបង្គាប់ឲ្យគេហៅខ្ញុំថាបែបនេះ។ ខ្ញុំមិនចង់ឲ្យអ្នកដទៃដាក់ឈ្មោះឲ្យខ្ញុំផ្សេងពីនេះទេ ព្រោះពួកគេគ្មានសិទ្ធិ។ បើប៉ាម៉ាក់របស់ខ្ញុំ មិនត្រូវការឈ្មោះផ្សេងសម្រាប់ហៅខ្ញុំ ខ្ញុំក៏មិនត្រូវការដែរ។ ម្យ៉ាងទៀត ឈ្មោះនេះ ក៏មិនអាក្រក់ស្តាប់ដែរ។ ឆ្នាំនេះ ខ្ញុំអាយុ២៣ឆ្នាំហើយ មិនទាន់រៀបការទេ បានន័យថា ក្នុងពេលប៉ុន្មានឆ្នាំទៀត ខ្ញុំនឹងត្រូវគេចាត់ទុកជាក្រមុំចាស់ម្នាក់មិនខាន។ បញ្ហាសំខាន់ គឺ ខ្ញុំមិនដែលគិតថា ការមិនទាន់រៀបការ មានអ្វីមិនល្អសោះ។ វាអាចមកពីខ្ញុំមិនទាន់យល់ ឬខ្ញុំយល់ផ្សេងពីអ្នកដទៃក៏ថាបាន។

រាល់ថ្ងៃ ខ្ញុំរស់ដោយសារ ការបង្រៀនភាសាអង់គ្លេស នៅសាលាតូចមួយក្បែរផ្ទះ។ ខ្ញុំមានសិស្សប្រហែលជា៣០នាក់ក្នុងត្រីមាសនេះ។ ខ្ញុំពេញចិត្តការបង្រៀនក្រៅម៉ោងបែបនេះ ព្រោះខ្ញុំអាចមានពេលនៅផ្ទះដើម្បីមើលរឿងភាគបាន។ គ្រួសារខ្ញុំមិនសូវធូរធារប៉ុន្មានទេ ព្រោះពេលខ្លះខ្ញុំលឺប៉ាម៉ាក់របស់ខ្ញុំតម្លើងសម្លេងដាក់គ្នា ព្រោះតែរឿងលុយកាក់។ ប្តីប្រពន្ធ បើមិនទាស់គ្នារឿងលុយ តើឲ្យទាស់គ្នារឿងអីទៀត?

ដោយសារថ្ងៃនេះជាថ្ងៃអាទិត្យ ហេតុនេះខ្ញុំអាចលំហែចិត្តរបស់ខ្ញុំជាមួយនឹងរឿងភាគបានហើយ។ ខ្ញុំទាញកៅអីទៅអង្គុយក្បែរបង្អួច ហើយយកទូរស័ព្ទមកបើកមើលរឿងបន្តភាគ។ ខ្ញុំមិនបាច់មានអ្នកណាមកមើលជាមួយខ្ញុំ ក៏ខ្ញុំអាចមានអារម្មណ៍រ៉ូមែនទិចម្នាក់ឯងបានដែរ។ ខ្ញុំពិតជាអរគុណដល់អ្នកដែល upload រឿងទាំងនេះចូល youtube ខ្លាំងណាស់។ ទោះបីជាពួកគេ upload ដោយគ្មានការអនុញ្ញាតក៏ដោយ ក៏ខ្ញុំនៅតែគិតថា ពួកគេជាមនុស្សចិត្តល្អដែរ។

**(ក្នុងរឿង)**

តួប្រុស ៖ តើអូនមានភស្តុតាងអីដែលចោទបងថា លួចក្បត់ចិត្តអូននោះ?

តួស្រី ៖ ភស្តុតាងខ្ញុំមិនមានទេ តែខ្ញុំដឹងថាបងលួចមានអ្នកថ្មីហើយ។

"លួចទៅអង្គុយជាមួយស្រីផ្សេងហើយ នៅសួរគេទាររកភស្តុតាងទៀត" ខ្ញុំគិតក្នុងចិត្ត ព្រោះកាលពីភាគមុន តួប្រុសនេះ អង្គុយជាមួយស្រីម្នាក់ផ្សេងទៀត។ ប្រពន្ធរវល់តែយំ ភ្លេចថតរូបទុកជាភស្តុតាង។ ឥលូវពេលនេះ គ្មានអ្វីតតាំងជាមួយគេទេ។ តែនេះជារឿងល្អ ព្រោះបើប្រពន្ធគ្មានភស្តុតាង ពួកគេអាចនឹងត្រូវគ្នាវិញ ហើយគ្រួសាររបស់គេក៏មិនបែកបាក់ដែរ។ អ្វីដែលប្រពន្ធបានឃើញ ជារឿងមិនពិតក៏ថាបាន។

ខ្ញុំកំពុងតែលង់ចិត្តជាមួយសមត្ថភាពវិភាគរឿងដ៏កំពូលរបស់ខ្ញុំ ស្រាប់តែលឺសម្លេងស៊ីផ្លេនៅមុខផ្ទះ។ ខ្ញុំស្គាល់សម្លេងនេះច្បាស់ណាស់។ ខ្ញុំទុកទូរស័ព្ទចុះ ហើយងើបដើរទៅបើកទ្វារឲ្យមិត្តភក្តិរបស់ខ្ញុំ។ ខ្ញុំសង្ឃឹមថាលើកនេះ មិត្តភក្តិខ្ញុំមិនយករឿងសង្សាររបស់គេមកនិយាយឲ្យខ្ញុំស្តាប់ទៅចុះ ព្រោះនិយាយទៅនិយាយមកគឺរឿងដដែល ហើយគ្មានប្តូរពាក្យទៀត។  ខ្ញុំមិនយល់ថា ហេតុអ្វីខ្ញុំត្រូវធ្វើខ្លួនជាពេទ្យចិត្តសាស្រ្ត ស្តាប់រឿងរបស់អ្នកដទៃបែបនេះសោះ។

មិត្តភក្តិមានទុក្ខ ខ្ញុំមិនអាចមិនអើពើបានទេ តែខ្ញុំអាចស្តាប់ហើយ បោះចោលបាន ព្រោះរឿងស្នេហារញ៉េររញ៉ៃបែបនេះ មិនមែនជាចំណូលចិត្តរបស់ខ្ញុំទេ។ ខ្ញុំមិនធ្លាប់មានស្នេហាច្បាស់លាស់ទេ ព្រោះរាល់ដងបើសិនជាមិនមែនខ្ញុំលួចស្រលាញ់គេទេ ក៏មានគេលួចស្រលាញ់ខ្ញុំដែរ។ ខ្ញុំគ្រាន់តែស្មានប៉ុណ្ណោះ ព្រោះមុខមាត់ខ្ញុំក៏មិនអាក្រក់ដល់ថ្នាក់គេខ្លាចដែរ ហើយម្យ៉ាងទៀត ខ្ញុំជាមនុស្សដែលមិនចេះប្រកាន់ខ្លួនទៀតផង។

ខ្ញុំបើកទ្វារ ហើយសម្លឹងទៅកាន់រូបរាងមនុស្សដែលនៅចំពីមុខផ្ទះខ្ញុំ។ ដោយសារថ្ងៃចាំងមកពីខាងក្រោយ ធ្វើឲ្យខ្ញុំមើលឃើញស្រមោលរបស់មិត្តភក្តិរបស់ខ្ញុំ ដែលឈរកៀក្បែរម៉ូតូ។ សុភារីណា ដោះមួកសុវត្ថិភាពចេញ ហើយដើរសំដៅមករកខ្ញុំ ក្នុងទឹកមុខមិនសូវល្អ។ ដូចខ្ញុំគិតទុកមែន ដល់ពេលដែលខ្ញុំត្រូវធ្វើជាពេទ្យចិត្តសាស្រ្តទៀតហើយ។

សុភារីណានិយាយក្នុងល្បឿនមួយដែលអាចប្រាប់ខ្ញុំថា វាកំពុងតែចង់ស្ទុះពីខាងក្នុង។ ខ្ញុំក៏បើកផ្លូវដើម្បីឲ្យកប៉ាលភ្លើងនេះបានដើរចូលផ្ទះរបស់ខ្ញុំ ដើម្បីបញ្ចេញផ្សែង។

"ឯងទំនេរដែរទេ?" សុភារីណាសួរបណ្តើរ និងដោះអាវក្រៅចេញបណ្តើរ។ ខ្ញុំមិនទាន់បានឆ្លើយផង សុភារីណា ក៏កាត់ខ្ញុំបន្តទៀត "ទោះឯងមិនទំនេរក៏មិនអីដែរ ព្រោះខ្ញុំត្រូវការនិយាយតែមួយភ្លែតប៉ុណ្ណោះ ហើយខ្ញុំនឹងទៅផ្ទះដេកហើយ។"

"អូខេ" ខ្ញុំឆ្លើយដោយដឹងជាមុនថា មួយភ្លែតរបស់វា យ៉ាងហោចណាស់ក៏មួយម៉ោងដែរ ទើបអាចចប់។ ខ្ញុំក្រឡេកមើលទៅទូរស័ព្ទរបស់ខ្ញុំ ដោយចិត្តស្តាយបន្តិច ព្រោះខ្ញុំមិនអាចតភាគបាន តែមិនអីទេ ព្រោះមិត្តភក្តិខ្ញុំគង់តែបញ្ចេញ drama របស់វាមកឥលូវហើយ។ រឿងដែលខ្ញុំមើល និងរឿងរបស់មិត្តភក្តិរបស់ខ្ញុំមិនសូវខុសគ្នាប៉ុន្មានទេ។ បើសិនជាពេលដែលវាកំពុងនិយាយ ហើយខ្ញុំចាក់ភ្លេងកំដរបន្តិច ខ្ញុំប្រាកដជាមានអារម្មណ៍ថា កំពុងនៅក្នុងរឿងតែម្តង។

"ឯងដឹងទេថា ថ្ងៃនេះបងពិសុទ្ធនិយាយអ្វីដាក់ខ្ញុំខ្លះ?" សុភារីណា សួរខ្ញុំ។ ខ្ញុំគ្រវីក្បាល ដើម្បីឲ្យវាដឹងថា ខ្ញុំកំពុងត្រៀមខ្លួនស្តាប់រឿង។

"គាត់ប្រាប់ខ្ញុំថា បើសិនជាយើងមិនអាចចុះសម្រុងគ្នាបានទេ យើងគួរតែឈប់ជួបគ្នាមួយរយៈសិនទៅ ដើម្បីឲ្យសម្រួលអារម្មណ៍បានរៀងខ្លួន" សុភារីណាបន្ត។ "គាត់ឲ្យខ្ញុំទុកពេលឲ្យគាត់គិតឡើងវិញ ព្រោះគាត់មិនដឹងថា ខ្ញុំ និងគាត់អាចរស់នៅជាមួយគ្នាបានឬអត់នៅថ្ងៃក្រោយ។ បើសិនជាខ្ញុំទុកពេលឲ្យគាត់ គាត់ច្បាស់ជាទៅមានអ្នកថ្មី ហើយភ្លេចខ្ញុំបាត់ហើយ។ បើធ្វើបែបនេះ ខ្ញុំជាអ្នកខាតទាំងស្រុង។"

ខ្ញុំសួរទៅវិញ "ខាតអ្វីខ្លះទៅ?"

"គឺខាតចិត្តដែលខ្ញុំខំស្រលាញ់គាត់។" សុភារីណាឆ្លើយ។

ខ្ញុំរំពឹងចម្លើយថា ខាតខ្លួន តែបែរជាបានចម្លើយផ្សេងទៅវិញ។ ខ្ញុំដឹងថាពីរនាក់មានអ្វីលើសពីចិត្តទៀត តែខ្ញុំធ្វើជាសួរបែបលេងបន្តិចទៅ កុំឲ្យវាគិតថា ខ្ញុំមិនចាប់អារម្មណ៍នឹងរឿងរបស់វាសោះ។

"ខ្ញុំខំស្រលាញ់គ្នាជាមួយគាត់រាប់ឆ្នាំហើយ ចង់ឲ្យខ្ញុំបោះបោលដោយងាយៗម៉េចនឹងកើត? ទោះបីជាកើត ក៏ខ្ញុំមិនចង់ធ្វើដែរ។" សុភារីណាបន្តដំណើររឿងដ៏អស្ចារ្យទៀត។ "តើខ្ញុំគួរធ្វើយ៉ាងម៉េច? ជួយឲ្យយោបល់ខ្លះមក។ ខ្ញុំទាល់គំនិតហើយពេលនេះ។" វាទម្លាក់មុខចិត្ត ធ្វើឲ្យខ្ញុំអានិត។

ខ្ញុំគិតមួយសន្ទុះ ហើយក៏និយាយវិញថា "ជាដំបូង ខ្ញុំបញ្ជាក់ឲ្យឯងដឹងច្បាស់បន្តិចសិន។ រាល់ដង ឯងមិនដែលមានគំនិតអ្វីទេ ហើយខ្ញុំជាអ្នកជួយប្រាប់ជានិច្ច ដូច្នេះឯងមិនបាច់ប្រាប់ខ្ញុំថា ឯងទាល់គំនិតហើយ ពេលនេះទេ ព្រោះវាជារឿងធម្មតាទៅហើយ។ ទីពីរ ខ្ញុំគិតថា ឯងដឹងថាត្រូវធ្វើអីរួចទៅហើយ ហេតុអីចាំបាច់មកសួរយោបល់ខ្ញុំ?"

សុភារីណា មិនរវល់នឹងឃ្លាដំបូងរបស់ខ្ញុំទេ វាក៏សួររំលងទៅឃ្លាទៅពីរថា "ខ្ញុំដឹងអី? ខ្ញុំមិនដឹងថាត្រូវធ្វើម៉េចផង?"

"ចុះក្រែងឯងថា មិនបោះបោលដោយងាយនោះអី? ឯងបន្តស្រលាញ់គាត់ទៀតទៅ។ ធ្វើដូចរាល់ដងទៅ ពេលណាឈ្លោះគ្នា ក៏ឈ្លោះទៅ ពេលណាត្រូវគ្នា ក៏ត្រូវគ្នាតាមធម្មតាទៅ មានអ្វីពិបាក?" ខ្ញុំឆ្លើយរំលឹងពីអ្វីមិត្តខ្ញុំបាននិយាយមុននេះ។

"តែធ្វើបែបហ្នឹង ខ្ញុំត្រូវពិបាកចិត្តគ្រប់ពេលហើយ។ ខ្ញុំទ្រាំមិនបានទេ ពេលដែលរឿងដដែលកើតឡើងបែបនេះ។" សុភារីណាឆ្លើយវិញ ដោយមានទឹកភ្នែករលីងរលោង។

"កុំទាន់អានយំ អាភា។ ខ្ញុំគិតថា ពាក្យដែលបងពិសុទ្ធនិយាយ ប្រហែលជាដំណោះស្រាយសម្រាប់បញ្ហារបស់ឯង។" ខ្ញុំហៅឈ្មោះមិត្តភក្តិរបស់ខ្ញុំ នៅពេលឃើញវារកយំបែបនេះ។ ខ្ញុំគិតថានេះជាវិធីលួងក្មេងដែលល្អបំផុត។ "ឯងគួរតែឈប់ជួបគាត់មួយរយៈសិន ដើម្បីឲ្យគាត់ និងឯងបានរំសាយអារម្មណ៍ខឹងគ្នា ហើយចាប់ផ្ដើម

នឹកគ្នាឡើងវិញ។ បើឯងធ្វើបែបនេះ អាចជួយឲ្យឯង និងគាត់មិនបាច់បែកគ្នាក៏ថាបាន។"

"ឯងច្បាស់ដែរទេ ថាគាត់មិនភ្លេចខ្ញុំ?" សុភារីណាសួររកធានាព្រាប់រងពីខ្ញុំទៀតហើយ។

"ខ្ញុំគ្មានអ្វីធានាឲ្យឯងទេ ប៉ុន្តែបើខ្ញុំមើលតាមរូបរាង និងមុខមាត់ឯង ជាពិសេសដើមទ្រូង ខ្ញុំគិតថា គាត់ក៏មិនចោលឯងដោយងាយដែរ។ មនុស្សប្រុស មិនល្ងង់បោះចោលរបស់ល្អបែបនេះទេ។ អូ! មិនមែនរបស់ទេ គឺមនុស្សស្រីល្អ។ ខ្ញុំច្រឡំមាត់បន្តិច។" ខ្ញុំឆ្លើយយករួចខ្លួន។

សុភារីណា អាចចាត់ទុកជាស្រីស្អាតជាងគេក្នុងចំណោមមិត្តភក្តិដែលខ្ញុំមានទាំងអស់។ វាមានសក់ត្រឹមស្មា ហើយលាបពណ៌ទង់ដែង ភាគច្រើនគឺចងឡើង ដោយទម្លាក់ចុះប៉ុន្មានសរសៃពីខាងមុខដើម្បីឲ្យមើលឃើញភាពទាក់ទាញ។ ខ្ញុំកម្រឃើញវាស្លៀកពាក់ខោអាវមិនសមរម្យណាស់ ទោះបីជានៅផ្ទះក៏ម៉ូតខោអាវរបស់វា ឈ្នះខោអាវដើរលេងរបស់ខ្ញុំដែរ។ មុខមាត់ អូខេ ដងខ្លួន អូខេ ក្លិនខ្លួន ក៏អូខេទៀត។ ខ្ញុំមិនយល់ថា ហេតុអ្វីបានជាវាត្រូវខ្វល់ខ្វាចគេបោះវាចោលនោះទេ? បើសិនជាខ្ញុំជាម៉ែយ៉ែម ខ្ញុំអាចដាក់លក់មិត្តភក្តិខ្ញុំមួយនេះ បានក្នុងតម្លៃលើសពី ១០០០ដុល្លារក្នុងមួយម៉ោង។ គួរឲ្យស្តាយ ខ្ញុំចាប់យកអាជីពជាគ្រូបង្រៀន កុំអីខ្ញុំក្លាយជាអ្នកមានបាត់។

សុភារីណាគិតបន្តិច រួចក៏និយាយមកកាន់ខ្ញុំវិញថា "បើខ្ញុំព្រមទុកពេលឲ្យគាត់ខ្លះតើយូរប៉ុណ្ណាដែលខ្ញុំគួរតែត្រូវគ្នាជាមួយគាត់វិញ?"

ខ្ញុំឆ្លើយ "សាកពីរអាទិត្យសិនទៅ វាមិនយូរប៉ុន្មានទេ។"

"អូខេ ចាំខ្ញុំទៅនិយាយជាមួយគាត់។ ប៉ុន្តែ..." សុភារីណាបម្រុងនឹងបន្ត តែខ្ញុំក៏និយាយកាត់មុន ព្រោះខ្ញុំដឹងថា បើសិនជាបើកដៃឲ្យនិយាយ ខ្ញុំច្បាស់ជាលែងបានមើលរឿងភាគខ្ញុំហើយ។

"មិនបាច់ប៉ុន្តែអីទេ សាកសិនទៅ បើសិនមិនកើត ចាំយើងគិតរកវិធីផ្សេងទៀត។" និយាយបណ្តើរ ខ្ញុំទាញយកអាវរបស់សុភារីណាមកពាក់ពីលើខ្លួនវាបណ្តើរ ហើយរុញវាតិចៗចេញពីផ្ទះខ្ញុំ។ "ទៅឲ្យលឿនទៅ កុំឲ្យហួសពេល។ រឿងស្នេហាឯងសំខាន់ណាស់ មិនអាចពន្យារពេលទៀតបានទេ។ ខ្ញុំនឹងផ្តល់កម្លាំងចិត្តឲ្យឯងពីផ្ទះខ្ញុំទៅ។" និយាយចប់ ខ្ញុំក៏រុញវាផុតមាត់ទ្វារ ឲ្យលើកដៃបាយបាយ រួចបិទទ្វារវិញ។ ខ្ញុំផ្ទៀងត្រចៀកស្តាប់ ទម្រាំលឺសូរសម្លេងម៉ូតូជិះចេញទៅ ទើបដើរមករកទូរស័ព្ទរបស់ខ្ញុំវិញ។

"ចប់រឿងដែលខ្ញុំមិនចង់ដឹង ឥលូវចូលមកដល់រឿងខ្ញុំចង់ដឹងវិញម្តង" ខ្ញុំនិយាយម្នាក់ឯង ដោយដៃកំពុងតែចុចបើករឿងមើលបន្ត។

**(ក្នុងរឿង)**

តួប្រុស ៖ អូនកុំទាន់សន្និដ្ឋានផ្តេសផ្តាស ប្រាប់បងសិនមក តើស្រីនោះមានមុខមាត់យ៉ាងម៉េច? ហើយអូនឃើញបងនៅម្តុំណា?

តួស្រី ៖ ខ្ញុំលែងចង់និយាយជាមួយបងឯងហើយ។

"យី! និយាយគ្នាមិនទាន់ដឹងអីផង យំស្រែកឡើងជោគខ្លួនទៅហើយ" ខ្ញុំលាន់មាត់ជាមួយនឹងសកម្មភាពហួសចិត្តរបស់តួស្រីនៅក្នុងរឿង។ ខ្ញុំបន្តការវិភាគរឿងរបស់ខ្ញុំដល់ម៉ោងជិត ៤ល្ងាច ទើបខ្ញុំងើបចូលទៅងូតទឹកបន្តិច កុំឲ្យឈឺក្បាល។ ល្ងាចនេះខ្ញុំដូចជាចង់ទៅអង្គុយនៅតាមហាងកាហ្វេបន្តិច ដើម្បីមើលអ្នកដទៃញ៉ែគ្នា។ ខ្ញុំគ្មានស្នេហាផ្ទាល់ខ្លួនទេ ហេតុនេះខ្ញុំត្រូវពឹងលើស្នេហារបស់អ្នកដទៃ មកបំពេញបេះដូងខ្ញុំ។

# ២

# គ្រួសារ

ខ្ញុំត្រលប់មកពីក្រៅវិញ ក៏ត្រូវចូលរង់បាយជាមួយគ្រួសាររបស់ខ្ញុំ និងដើម្បីស្ដាប់ពួកគាត់និយាយគ្នាពីការងារប្រចាំថ្ងៃរបស់គាត់។ ខ្ញុំជាកូនទោល ហេតុនេះបើខ្ញុំមិននិយាយជាមួយប៉ាម៉ាក់ ខ្ញុំក៏គ្មានអ្នកនិយាយជាមួយដែរ។ ម៉ាក់ខ្ញុំ ជាអ្នកបោសសម្អាតតាមសាលារៀន។ គាត់ធ្វើការនៅសាលាដែលខ្ញុំទៅបង្រៀន គ្រាន់តែគាត់ធ្វើការពេញម៉ោង ហើយខ្ញុំធ្វើការតែមួយកំណាត់ថ្ងៃ។ ប៉ាខ្ញុំ ជាជាងកាត់ដេរ។ គាត់ស៊ីឈ្នួលកាត់ខោអាវឲ្យគេប៉ុណ្ណោះ។ ខ្ញុំមិនប្រកាន់នឹងការងាររបស់ពួកគាត់ ព្រោះការងារខ្ញុំ ក៏គ្មានអ្វីអស្ចារ្យដូចគ្នា។

ម៉ាក់ខ្ញុំចាប់ផ្ដើមកិច្ចសន្ទនាមុនគេ ដោយនិយាយថា “ស្អែកដល់ថ្ងៃធ្វើការទៀតហើយ។ ឈប់ដូចមិនបានឈប់សោះរាល់ថ្ងៃនេះ។”

ប៉ាខ្ញុំក៏លូកមាត់បន្ត “យើងមានការងារធ្វើ គ្រាន់បើហើយ អ្នកខ្លះស៊ីអត់ស៊ីឃ្លានតាមផ្លូវ ទើបពិបាក។ ស្អែកបងត្រូវទៅពីព្រឹកបន្តិច ព្រោះត្រូវហួសទៅយកអាវពីម៉ូយមកកាត់បន្ថែម។”

“អូ! បើទៅពីព្រឹក ចាំខ្ញុំឡើងធ្វើបាយទឹក កុំឲ្យខាតលុយទៅបាយខាងក្រៅ។” ម៉ាក់ខ្ញុំនិយាយ។ ពួកគាត់ តែងតែគិតពីរឿងសន្សំសំចៃជានិច្ច លើកលែងតែខ្ញុំទេ ដែលចាយវាយផ្ដេសផ្ដាស។

“មនោរា ល្ងាចមិញ ពេលម៉ាក់មកផ្ទះល្ងាច ឃើញអាភាជិះចេញពីច្រកផ្ទះយើង។ វាមកមានការអី ឃើញបើកម៉ូតូលឿនណាស់ ដូចជាប្រញាប់ទៅណា?” ម៉ាក់ខ្ញុំសួរ។

គាត់ស្គាល់អាភាយូរឆ្នាំហើយ គឺតាំងពីពេលដែលខ្ញុំនឹងអាភារៀនថ្នាក់ជាមួយគ្នាដំបូងមកម្ល៉េះ។ បើរាប់ទៅប្រហែលជា ៥ឆ្នាំហើយ។

ខ្ញុំប្រឹងទំពារបាយក្នុងមាត់ឲ្យឆាប់អស់ ដើម្បីឆ្លើយតបទៅគាត់ "អាភា វាមករកឲ្យជួយឲ្យយោបល់រឿងស្នេហា។ វាឈ្លោះគ្នាជាមួយសង្សារវាទៀតហើយ។"

ម៉ាក់ខ្ញុំទម្លាក់ស្លាបព្រាចុះ ហើយធ្វើមុខដូចជាឆ្ងល់ រួចនិយាយថា "អ្នកចេះហែលទឹកសួរអ្នកមិនចេះហែលទឹក ថាត្រូវហែលទឹកបែបណា។" ខ្ញុំដឹងថាគាត់ចង់ថាឲ្យខ្ញុំ។

"ខ្ញុំមិនធ្លាប់មានស្នេហាមែន តែខ្ញុំធ្លាប់មើលរឿងច្រើន។" ខ្ញុំឆ្លើយដោយមានទំនុកចិត្តលើខ្លួនឯង។ ខ្ញុំមិនដែលគិតថា ខ្លួនខ្ញុំល្ងង់ក្នុងរឿងស្នេហានោះទេ។

"ត្រូវហើយ ម៉ាក់ភ្លេច។ អ្នកមិនចេះហែលទឹក គ្រាន់តែមើលអ្នកដទៃហែល ក៏អាចចេះបានដែរ។" ម៉ាក់ខ្ញុំនៅតែយកការប្រៀបធៀបរបស់គាត់មកនិយាយដដែល។ "ហើយចុះកូនប្រាប់អាភាថាម៉េចខ្លះ?"

"ខ្ញុំប្រាប់ឲ្យអាភា ផ្អាកជួបគ្នាជាមួយសង្សារវាមួយរយៈសិនទៅ កុំឲ្យនៅឈ្លោះគ្នាដដែលទៀត។" ខ្ញុំឃើញគាត់បម្រុងនឹងនិយាយបន្ត ខ្ញុំក៏និយាយកាត់មុនថា "នេះមិនមែនជាគំនិតខ្ញុំទេ ជាគំនិតរបស់សង្សារអាភា។ ខ្ញុំគ្រាន់តែស្រែកហ៊ោរតាមក្រោយប៉ុណ្ណោះ។"

ម៉ាក់ខ្ញុំគ្រវីក្បាល ហើយសួរថា "ចុះបើផ្អាកជួបគ្នាហើយ លែងជួបគ្នារហូត កូនឯងមិនក្លាយជាអ្នកចាក់រុកគេឲ្យបែកគ្នាទៅហើយ?"

ខ្ញុំញញឹមហើយនិយាយថា "ចាំមើលសិនទៅម៉ាក់ គ្មានអ្នកណាអាចទាយដឹងពីអនាគតទេ។ ពីរនាក់នេះស្រលាញ់គ្នាយូរហើយ ប្រហែលជាមិនអីទេ។"

យើងក៏ប្តូរប្រធានបទទៅនិយាយពីការងារដេរខោអាវរបស់ប៉ាវិញ ដើម្បីកុំឲ្យប៉ាស្ងាត់មាត់យូរពេក។

**ម៉ោង ៩យប់**

ខ្ញុំកំពុងតែអង្គុយអានសៀវភៅមេរៀនអង់គ្លេសរបស់ខ្ញុំ។ ទោះបីខ្ញុំបង្រៀនក្មេងមែន តែខ្ញុំមិនដែលភ្លេចត្រៀមខ្លួនឲ្យបានមុនទេ។ ខ្ញុំអានឲ្យហើយពេលនេះ ព្រឹកឡើងខ្ញុំអាចអង្គុយមើលរឿងភាគបាន ដោយមិនបាច់ភ័យ។

សម្លេងញ័រៗ បានលឺចេញពីក្រោមភួយរបស់ខ្ញុំ។ បើខ្ញុំទាយមិនខុសទេ គឺអាភា រាយការណ៍ប្រាប់ខ្ញុំពីអ្វីដែលវាបានធ្វើមិនខាន។ ខ្ញុំយកទូរស័ព្ទមកបើកអានសារ។ តាមពិតមានសារថ្មីពីរនៅក្នុង inbox របស់ខ្ញុំ។ មួយ គឺអាភា ហើយមួយទៀត គឺក្រុមហ៊ុន smart ផ្ញើសារប្រាប់ឲ្យខ្ញុំដាក់ call tune។ ហេតុអ្វីខ្ញុំត្រូវបង់លុយ ដើម្បីអ្នកដទៃបានស្តាប់ចម្រៀង? ខ្ញុំចុចលុបចោល ហើយបើកសាររបស់អាភាមើល។

"ខ្ញុំប្រាប់គាត់រួចហើយ គាត់យល់ព្រម ហើយគាត់ថា ចាំពីរអាទិត្យទៀត ចាំជួបគ្នា។ គាត់ក៏ចង់ដកខ្លួនពីការឈ្លោះគ្នារាល់ថ្ងៃបែបនេះសិនដែរ។" អាភារៀបរាប់ក្នុងសារ

ខ្ញុំសង្ឃឹមថា ពីរនាក់នេះមិនកើតអីចុះ ព្រោះបើមានអ្វីមិនស្រួល ហើយពីរនាក់នេះពិតជាបែកគ្នាមែន ខ្ញុំច្បាស់ជាត្រូវស្តាប់អាភារៀបរាប់ពីទុក្ខលំបាករបស់វាទៀតហើយ។ ខ្ញុំមិនចង់ស្តាប់វានិយាយផង យំផង ហើយមានសម្លេងសំបោរទៀតទេ។ គួរឲ្យខ្លាច។

ខ្ញុំក៏តបសារវិញថា "កុំភ័យពេក ធ្វើជម្មតាសិនទៅ។"

ខ្ញុំបម្រុងនឹងចាប់ការងារមកធ្វើបន្ត ម៉ាក់ក៏ចូលមកបន្ទប់ខ្ញុំ។ គាត់យកទឹកមួយដបមកឲ្យខ្ញុំ សម្រាប់ពេលយប់។

“រវល់ ឬអត់? បើរវល់ ម៉ាក់ទៅវិញ។” ម៉ាក់សួរ ព្រោះឃើញសៀវភៅនៅរាយប៉ាយពេញតុ។

“អត់អីទេ” ខ្ញុំប្រាប់គាត់វិញ។ ខ្ញុំក៏មានរឿងចង់សួរគាត់ដែរ។

“ម៉ាក់រកគ្នានិយាយលេង ព្រោះប៉ាឯងសំរាន្តបាត់ហើយ។” គាត់ចាប់យកក្រដាសព្រៀងមេរៀនរបស់ខ្ញុំទៅមើល ហើយនិយាយថា “អក្សរស្អាតដល់ហើយ។ អីចឹងបានជាមិនបានរៀនពេទ្យ បានត្រឹមតែធ្វើគ្រូអង់គ្លេស។”

“ខ្ញុំមិនដែលចង់ធ្វើពេទ្យផង” ខ្ញុំប្រកែកទៅវិញ។ សំនួរមួយលេចឡើងមួយរំពេចក្នុងខួរក្បាលខ្ញុំ។ ខ្ញុំគួរតែសួរម៉ាក់ឲ្យហើយល្អជាង។ “កាលពីក្មេង ម៉ាក់ធ្លាប់មានបញ្ហាស្នេហាដូចអាភាឬអត់?”

ម៉ាក់ញញឹមបន្តិច ហើយនិយាយថា “រឿងអីមិនធ្លាប់ ហើយធ្លាប់ច្រើនដងទៀតផង។”

“wow! និយាយប្រាប់ខ្ញុំបន្តិចទៅមើល ថាម៉ាក់មានអារម្មណ៍យ៉ាងម៉េចខ្លះ ហើយម៉ាក់ដោះស្រាយយ៉ាងម៉េច?” ខ្ញុំសួរបន្តទៀត។

ម៉ាក់ទម្លាក់ក្រដាសរបស់ខ្ញុំចុះ ហើយចាប់ផ្តើមនិយាយពីបទពិសោធន៍ស្នេហារបស់គាត់ឲ្យខ្ញុំស្តាប់។ “មុនស្គាល់ប៉ារបស់កូន ម៉ាក់ធ្លាប់មានសង្សារ៣នាក់ តែមិនធ្លាប់ខូចខ្លួនជាមួយអ្នកណាទេ។ ម៉ាក់តែងតែមិនទុកចិត្តថា អ្នកដែលស្រលាញ់ម៉ាក់ទាំងនោះ មិនរត់ចោលម៉ាក់ក្រោយពេលបានខ្លួនបានអីហើយ។ សង្សារដែលម៉ាក់ធ្លាប់មានយូរបំផុត គឺ៣ឆ្នាំ ហើយលឿនបំផុត គឺ ៦ខែ។” គាត់មើលមុខខ្ញុំបន្តិច ហើយក៏និយាយបន្ត។

“រាល់ពេលដែលឈ្លោះគ្នា ម៉ាក់មិនដឹងថាត្រូវធ្វើបែបណាឲ្យត្រូវទេ ព្រោះបើម៉ាក់កាន់តែព្យាយាមសម្របសម្រួល គឺកាន់តែឈ្លោះគ្នាខ្លាំងឡើង។ វាអាចមកពីម៉ាក់នៅក្មេង

ហេតុនេះមិនអាចគ្រប់គ្រងអារម្មណ៍ខ្លួនឯងបាន។ កូនមិនធ្លាប់មានស្នេហា កូនមិនយល់ពីអារម្មណ៍ទាំងនោះទេ។ ពេលបែកគ្នា គឺពិបាកណាស់។” ម៉ាក់ឈប់មួយភ្លែត ហើយនិយាយបន្ត។

“អ្វីដែលម៉ាក់សម្គាល់ទុក គឺ រាល់ពេលដែលឈ្លោះគ្នាខ្លាំងហើយ គ្រប់យ៉ាងគឺចប់តែម្តង មិនអាចបកក្រោយវិញបានទេ។ រហូតដល់ពេលដែលម៉ាក់ស្គាល់ប៉ាកូន ទើបម៉ាក់រៀនចេះពីវិធីដោះស្រាយរឿងអារម្មណ៍ពេលបែកគ្នា។ ប៉ាកូនប្រាប់ម៉ាក់ថា ពេលមានរឿងពិបាកកើតឡើង ត្រូវដោះស្រាយដោយប្រើអារម្មណ៍មនុស្សប្រុស។ កុំសួរថា បើរឿងនេះកើតឡើង តើមនុស្សស្រីនឹងធ្វើបែបណា? ត្រូវគិតឲ្យផ្ទុយពីអ្វីដែលអ្នកដទៃធ្វើ។ មនុស្សស្រីយើង មិនពូកែខាងគ្រប់គ្រងអារម្មណ៍ទេ ហេតុនេះទើបយើងត្រូវប្រយ័ត្នចំពោះអារម្មណ៍ខ្លួនឯង។ យើងមិនគួរឲ្យអារម្មណ៍របស់យើងធ្វើបាបយើងទេ។ ” ម៉ាក់ផ្អាកមួយភ្លែតហើយយកដៃមកអង្អែលក្បាលខ្ញុំ។

គាត់ក៏និយាយបន្ត “ម៉ាក់ដឹងថាកូនអាចយល់ពីរឿងនេះនៅថ្ងៃណាមួយ ហើយបើដល់ថ្ងៃនោះនៅតែមិនយល់ ចាំមកសួរម៉ាក់ម្តងទៀតក៏បានដែរ។ ម៉ាក់នៅក្មេងមិនទាន់ទៅណាទេ។” ខ្ញុំសើចដាក់គាត់។ គាត់ក៏ងើបឡើង ហើយនិយាយថា “ធ្វើការងារកូនឲ្យហើយទៅ កុំចង់ដឹងរឿងស្នេហាច្រើនពេក ព្រោះកូនគង់តែបានដឹងដោយខ្លួនឯងដែរ។ តើកូនស្អប់អ្នកដែលមើលរឿងហើយមុនកូនមកនិយាយប្រាប់កូនពីសាច់រឿងដែរទេ?” គាត់សួរខ្ញុំ។

“ស្អប់ដល់ពោះវៀន ដឹងហើយមកនិយាយឲ្យអ្នកគេអស់កន្លែងភ្ញាក់ផ្អើល។” ខ្ញុំឆ្លើយវិញដោយប្រញាប់ តែខ្ញុំមិនដឹងថាគាត់សួរធ្វើអីទេ ព្រោះវាដូចជាមិនទាក់ទងគ្នាសោះ។

“ម៉ាក់ក៏មិនចង់ប្រាប់កូនច្រើនពេកដែរ ម៉ាក់ចង់ឲ្យកូនដឹងដោយខ្លួនឯង ប្រហែលជាល្អជាង។” ម៉ាក់ខ្ញុំនិយាយ ហើយក៏ដើរចេញទៅ។

តាមពិតគាត់មិនចង់និយាយប្រាប់ខ្ញុំសោះ ទើបសួរសំណួរនោះ។ បើគាត់ទុកស្នេហារបស់គាត់ ជារឿងកុន តើគាត់ទុកខ្ញុំជាអ្វីទៅ? ខ្ញុំជាផលិតផលរបស់ស្នេហាគាត់។ ចាំពេលណាទំនេរ ខ្ញុំនឹងសួរម៉ាក់ខ្ញុំពីរឿងនេះទៀត។

ខ្ញុំនៅតែមិនសូវយល់ តើឲ្យខ្ញុំគិតដូចមនុស្សប្រុសបានយ៉ាងម៉េចទៅ? ខ្ញុំធ្លាប់អានអត្ថបទលើអ៊ីនធឺណេតដែលគេសរសេរថា មនុស្សប្រុសគិតពីរឿងផ្លូវភេទពេញមួយថ្ងៃ។ តើពេលពួកគេបែកបាក់ស្នេហា ពួកគេគិតពីរឿងនេះមែនទេ ទើបអាចរម្ងាប់អារម្មណ៍គេបាន?

ខ្ញុំគិតថា បើសិនជាខ្ញុំមានស្នេហា ខ្ញុំគួរតែត្រៀមខ្លួនសម្រាប់ពេលបែកគ្នាឲ្យហើយ ព្រោះបើពេលនោះមកដល់ ខ្ញុំក៏មិនសូវពិបាកដូចអាភា រត់ចុះរត់ឡើង បែបនេះដែរ។ ខ្ញុំមិនអាចទៅសួរយោបល់អាភាបានទេ ព្រោះអាភាគ្មានយោបល់ផ្ទាល់ខ្លួន។ បើទៅសួរវា វាច្បាស់ជាសួរខ្ញុំវិញ ហើយខ្ញុំជាអ្នកឆ្លើយដោយខ្លួនឯងដដែលទេ។

កុំថាតែត្រូវយល់ពីការគិតដូចមនុស្សប្រុស សូម្បីតែគិតដូចមនុស្សស្រី ក៏ខ្ញុំមិនយល់ដែរ។ ខ្ញុំមិនទាំងដឹងថា មនុស្សស្រីធ្វើអ្វីខ្លះផង ពេលដែលពួកគេមានបញ្ហាស្នេហា។ អាភារត់មករកខ្ញុំដើម្បីសួរយោបល់មែន តែមិនធ្លាប់ប្រាប់ខ្ញុំពីអារម្មណ៍របស់វាទេ។ វាលាក់អារម្មណ៍របស់វាបានល្អណាស់ វានិយាយច្រើន តែសូម្បីតែបន្តិច ក៏មិនពាក់ព័ន្ធនឹងអារម្មណ៍របស់វាដែរ។ ខ្ញុំមិនទាន់មានស្នេហាផង មានរឿងច្រើនដល់ថ្នាក់នេះហើយ ចុះទម្រាំមានខ្លួនឯងទៀត តើខ្ញុំត្រូវជួបរឿងអ្វីខ្លះ?

មុននេះ ម៉ាក់ប្រាប់ថា គាត់ធ្លាប់មានសង្សារ៣នាក់ តែគ្មានអ្នកណាធ្វើស៊ីគាត់បានទេ។ តើមកពីគាត់ឆ្លាត ឬមកពីប្រុសទាំងនោះល្ងង់? តើនេះបានន័យថា ប៉ារបស់ខ្ញុំឆ្លាតជាងប្រុសប៉ុន្មាននាក់នោះមែនទេ? ឈប់សិន! រឿងឆ្លាត ឬមិនឆ្លាត មិនអាចកំណត់ដោយការធ្វើស៊ីមនុស្សស្រីទេ។ ជួនកាលពួកគេ អាចគោរពម៉ាក់ខ្ញុំក៏ថាបាន។ ហើយរួចចុះ គាត់ធ្វើម៉េចឲ្យគេគោរពគាត់? សូម្បីតែសិស្សដែលខ្ញុំបង្រៀន ក៏មិនគោរពខ្ញុំផង។ ខ្ញុំដូចជាឆ្ងល់ច្រើនពេកហើយ អានមេរៀនខ្ញុំឲ្យហើយវិញ។